១.២ ការបើកគណនីរបស់ខ្ញុំ/យើងខ្ញុំនេះ ត្រូវស្របទៅតាមលក្ខខណ្ឌតម្រូវរបស់ធនាគាររួមមាន ប្រាក់បញ្ញើ អប្បបរមា អាយុ និងឯកសារយោងផ្សេងៗ។

### ២. សេចក្តីអនុញ្ញាត និង សំណើ

ខ្ញុំ/យើងខ្ញុំ អនុញ្ញាត និងស្នើសុំអោយធនាគារគោរព និងអនុវត្តតាមប័ណ្ណដកប្រាក់ រឺបែបបទសមស្រប ដែលចេញដោយធនាគារសំរាប់ការដកប្រាក់មួយចំនួន រឺទាំងអស់នៅក្នុងគណនីណាមួយរបស់ខ្ញុំ/យើងខ្ញុំ និងរាល់អនុទ្ទេសជាលាយលក្ខណ៍អក្សររបស់ខ្ញុំ/យើងខ្ញុំ ក្នុងការផ្ញើ ការដកហូត រឺលក់មូលបត្រ (Securities) លិខិតកាន់កាប់ (Deeds) រឺឯកសារផ្សេងៗ រឺទ្រព្យសម្បត្តិនានា (រួមមានទូសុវត្ថិភាពសម្រាប់ប្រាក់បញ្ញើ និងវត្ថុរួមផ្សំ) រឺអ្វីៗក៏ដោយដែលស្ថិតនៅក្រោមការកាន់កាប់របស់ធនាគារសម្រាប់គណនីរបស់ខ្ញុំ/យើងខ្ញុំ ទោះបីតាមរយៈការ ធានា រឺទូដែកសុវត្ថិភាព រឺតាមមធ្យោបាយផ្សេងទៀត។

### ៣. ការដាក់ និង ការដកប្រាក់បញ្ញើ

៣.១ ខ្ញុំ/យើងខ្ញុំយល់ព្រម និងសន្យាថា រាល់ការដាក់ប្រាក់បញ្ញើទាំងអស់ត្រូវអមដោយប័ណ្ណដាក់ប្រាក់បញ្ញើ រឺអមដោយទំរង់លិខិតណាមួយចេញដោយធនាគារ រឺលិខិតណាមួយស្របទៅតាមលក្ខខណ្ឌតម្រូវរបស់ធនាគារ។ បង្កាន់ដៃដែលចេញដោយធនាគារ ចាត់ទុកថាមានសុពលភាពដរាបណាតែបង្កាន់ដៃនេះត្រូវបានចេញដោយម៉ាស៊ីនរបស់ធនាគារ រឺទទួលស្គាល់ដោយមន្ត្រីប្រតិស្រុតរបស់ធនាគារ។ ខ្ញុំ/យើងខ្ញុំ ត្រូវពិនិត្យមើលអោយបានជាក់លាក់ថាសកម្មភាពទាំងនេះ ត្រូវបានបំពេញសព្វគ្រប់មុនពេលចាកចេញពីបរិវេណរបស់ធនាគារ។

៣.២ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់ការដកប្រាក់ចេញពីគណនីសន្សំរបស់ខ្ញុំ/យើងខ្ញុំ ត្រូវតែធ្វើឡើងដោយខ្ញុំ/យើងខ្ញុំផ្ទាល់ ហើយត្រូវភ្ជាប់មកជាមួយនូវប័ណ្ណដកប្រាក់ រឺតាមទំរង់លិខិតណាមួយចេញដោយធនាគារ រឺតាមការបង្ហាញសៀវភៅធនាគារ រឺតាមការបង្ហាញអត្តសញ្ញាណណាមួយ។ ធនាគារអាចតម្រូវឱ្យបង្ហាញភស្តុតាងនានា ដែលអាចបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្ញុំ/យើងខ្ញុំបាន។ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា រាល់ការដកប្រាក់តាមរយៈម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (ATM) ត្រូវគោរពតាមលក្ខខណ្ឌអនុវត្តសម្រាប់ម៉ាស៊ីន ATM។

៣.៣ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់មូលប្បទានប័ត្រ និងលិខិតុបករណ៍ដែលបានតម្កល់នៅធនាគារអាចទទួលយកបានសម្រាប់តែបេឡានិច័យប៉ុណ្ណោះ លើកលែងតែមានការចាត់ចែងជាពិសេសណាមួយ ហើយរាល់មូលប្បទានប័ត្រ និងលិខិតុបករណ៍ដែលបានតម្កល់នៅធនាគារទាំងអស់នោះ មិនអាចទូទាត់បានឡើយ លុះណាតែធនាគារទទួលបានសមតុល្យ ហើយធនាគារមានសិទ្ធិបដិសេធក្នុងការធ្វើបេឡានិច័យចំពោះមូលប្បទានប័ត្រណា ដែលធនាគារយល់ថាមានលក្ខណៈមិនប្រក្រតីដោយប្រការណាមួយ រឺការកែប្រែណាមួយ លើកលែងតែ ការកែប្រែនោះ មានហត្ថលេខាអមដោយបហារ៉ក។

៣.៤ ខ្ញុំ/យើងខ្ញុំ ទទួលខុសត្រូវលើការចេញសំណងជូនធនាគារដែលដើរតួជាធនាគារបេឡានិច័យសម្រាប់រាល់ការខាតបង់ ដែលធនាគារបានជួបប្រទះ ទៅលើរាល់ការធានាលើរូបិយបដិភាគ រឺការទូរទាត់មូលប្បទានប័ត្រ វិក្កយបត្រប័ណ្ណរូបិយាណត្តិ ភាគលាភ សក្ខីប័ត្រ រឺលិខិតុបករណ៍ផ្សេងទៀតដែល ខ្ញុំ/យើងខ្ញុំបានបង្ហាញ សម្រាប់ ធ្វើបេឡានិច័យនិងរាល់ការធានាដែលផ្តល់ដោយធនាគារនឹងត្រូវបានចាត់ទុកថា ខ្ញុំ/យើងខ្ញុំបានស្នើសុំទៅ ធនាគារចំពោះគ្រប់ករណីខាងលើ។

៣.៥ ខ្ញុំ/យើងខ្ញុំយល់ព្រមបន្ថែមពីលើលក្ខខណ្ឌដែលបានរៀបរាប់ខាងលើនេះថា ខ្ញុំ/យើងខ្ញុំត្រូវគោរពតាមលក្ខខណ្ឌដែលបោះពុម្ពនៅលើសៀវភៅគណនីសន្សំរបស់ខ្ញុំ/យើងខ្ញុំ រឺលក្ខខណ្ឌនៅលើសន្លឹកប័ណ្ណ រឺខិត្តប័ណ្ណផ្សេងៗ រឺនៅផ្នែកខាងក្រោយរបស់លិខិតប្រាក់បញ្ញើ ដែលភ្ជាប់ជាមួយនឹងស្រោមសំបុត្រមូលប្បទានប័ត្រ ប្រាក់បញ្ញើ និងលក្ខខណ្ឌពិសេសផ្សេងទៀតដែលកំណត់ជាប្រចាំដោយធនាគារ។

## ខ. គណនីចរន្ត

### ១. ការបើកគណនី

ការបើកគណនីចរន្តរបស់ខ្ញុំ/យើងខ្ញុំ ត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌទាំងឡាយ និងលក្ខខណ្ឌជាក់លាក់ផ្សេងទៀតដែលមានជាធរមានចំពោះគណនីចរន្តជាមួយនឹងលក្ខខណ្ឌពិសេស រឺរួមផ្សំជាមួយនឹងគណនីសន្សំ ដែលកំណត់នៅក្នុងពាក្យស្នើសុំបើកគណនីជាក់លាក់ និងខិត្តប័ណ្ណ (តទៅនេះហៅថាលក្ខខណ្ឌពិសេសគណនីចរន្ត) ហើយខ្ញុំ/យើងខ្ញុំយល់ព្រមគោរពតាមលក្ខខណ្ឌជាក់លាក់នៃគណនីចរន្ត ដែលកំពុងមានសុពលភាពនាពេលបច្ចុប្បន្ន ហើយដែលអាចកែប្រែ រឺធ្វើវិសោធនកម្មជាប្រចាំ ដោយមាន រឺគ្មានការជូនដំណឹងជាមុន។

### ២. ការដាក់ពាក្យសុំសៀវភៅមូលប្បទានប័ត្រ និង លក្ខខណ្ឌគ្រប់គ្រងមូលប្បទានប័ត្រ

២.១ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់ការស្នើសុំសៀវភៅមូលប្បទានប័ត្រ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម បែបបទកំណត់ដោយធនាគារ រឺលិខិតស្នើសុំជាលាយលក្ខណ៍អក្សរ ហើយយល់ព្រមថាមូលប្បទានប័ត្រនេះ នឹងមិនអាចប្រើបានឡើយ លុះណាតែធ្វើឡើងតាមបែបបទដែលបានផ្តល់អោយ រឺបានចុះបញ្ជីសម្រាប់គោលបំណងនេះ។ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា មូលប្បទានប័ត្រអាចប្រើប្រាស់បានសម្រាប់តែដកប្រាក់ចេញពីគណនីធនាគារ ដែលធនាគារកំណត់ថាជាគណនីចរន្ត រឺគណនីផ្សេងទៀតដែលធនាគារបានកំណត់ជាប្រចាំ ។

២.២ បន្ថែមពីលើលក្ខខណ្ឌដែលបានរៀបរាប់ខាងលើនេះ ខ្ញុំ/យើងខ្ញុំយល់ព្រមគោរពតាមលក្ខខណ្ឌដែលមានបោះពុម្ពលើគំរបសៀវភៅមូលប្បទានប័ត្រ និងលើលិខិតប្រាក់បញ្ញើភ្ជាប់ជាមួយនឹងផ្នែកខាងក្រោយនៃស្រោមសំបុត្រមូលប្បទានប័ត្រប្រាក់បញ្ញើ។

២.៣ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមានសិទ្ធិក្នុងការបដិសេធមូលប្បទានប័ត្រណាដែលមានចុះហត្ថលេខាខុសពីគំរូហត្ថលេខាដែលបានផ្តល់អោយធនាគារ រឺមានលក្ខណៈមិនប្រក្រតីណាមួយ (តាមមតិរបស់ធនាគារ)។ ដោយមិនគិតពីលក្ខណៈទូទៅនៃដំណើរការនេះ គ្មានការផ្លាស់ប្តូរណាមួយត្រូវបានធ្វើឡើងនៅលើមូលប្បទានប័ត្រឡើយ។ ធនាគាររក្សាសិទ្ធិបដិសេធ និងប្រគល់ជូនវិញនូវមូលប្បទានប័ត្រណាដែលមានការកែប្រែទោះតាមទំរង់ណាក៏ដោយ យោងតាមមតិដាច់ខាតរបស់ធនាគារ (ទោះបីមាន រឺមិនមានហត្ថលេខាអមរបស់ខ្ញុំ/យើងខ្ញុំ)។

២.៤ ខ្ញុំ/យើងខ្ញុំយល់ព្រមបន្ថែមទៀតថា មូលប្បទានប័ត្រដែលមានឆូត "A/C អត្ថាគាហកប៉ុណ្ណោះ" (A/C Payee only) នឹងត្រូវបានបង់ប្រាក់ចូលតែទៅក្នុងគណនីរបស់អត្ថាគាហកដែលបានចែងប៉ុណ្ណោះ។ មូលប្បទានប័ត្រដែលមានឆូត "គណនីអត្ថាគាហកប៉ុណ្ណោះ" (Account Payee only) ដែលត្រូវបានលុបចោល និងមានហត្ថលេខាអមរបស់ខ្ញុំ/យើងខ្ញុំដោយយោងតាមគំរូហត្ថលេខារបស់ខ្ញុំ/យើងខ្ញុំ នឹងអាចបង់ជាសាច់ប្រាក់បាននៅពេលដែលខ្ញុំ/យើងខ្ញុំ រឺភាគីទីបីណាមួយ បង្ហាញមូលប្បទានប័ត្រសម្រាប់ការបង់ប្រាក់។ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមានសិទ្ធិយក កម្រៃសេវាកម្មពីខ្ញុំ/យើងខ្ញុំ ប្រសិនបើមូលប្បទានប័ត្រនេះ ត្រូវបានបើកជាសាច់ប្រាក់ដោយ ភាគីទីបីណាមួយ។

២.៥ ខ្ញុំ/យើងខ្ញុំយល់ព្រម និង ធានាអះអាងថា រាល់អនុទ្ទេសអោយបញ្ឈប់រាល់ការបង់ប្រាក់នៃមូលប្បទានប័ត្រ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយផ្តល់នូវព័ត៌មានដូចតទៅ: (១) លេខមូលប្បទានប័ត្រ (២)កាលបរិច្ឆេទរបស់មូលប្បទានប័ត្រ (៣)ឈ្មោះរបស់អត្ថាគាហក និង (៤)ចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រ ហើយអនុទ្ទេសនេះ នឹងមានសុពលភាពបន្ទាប់ពីធនាគារបានទទួលអនុទ្ទេសនេះប៉ុណ្ណោះ។ ធនាគារមិនទទួលខុសត្រូវចំពោះភាពយឺតយ៉ាវ រឺ

លុបចោលការអនុវត្តអនុទ្ទេសនេះឡើយ ។ ខ្ញុំ/យើងខ្ញុំយល់ព្រមដែរថា ធនាគារមានឆន្ទានុសិទ្ធិក្នុងការបញ្ឈប់ រឺមិនបញ្ឈប់នូវអនុទ្ទេសបង់ប្រាក់សម្រាប់មូលប្បទានប័ត្រទទេ (Blank checques) រឺមូលប្បទានប័ត្រណាដែលបានបាត់ ត្រូវបានលួច រឺដែលធ្វើអោយមានការភន្ត័ច្រឡំ ហើយធនាគាររក្សាសិទ្ធិមិនបញ្ឈប់នូវអនុទ្ទេសបង់ប្រាក់សម្រាប់មូលប្បទានប័ត្រណាដែលបានបង់ប្រាក់ហើយ ពេញលេញ និងជាស្ថាពរ ។ ខ្ញុំ/យើងខ្ញុំយល់ព្រមថារាល់ការបញ្ឈប់អនុទ្ទេស បង់ប្រាក់ត្រូវអស់សុពលភាពក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរបស់អនុទ្ទេសនោះ ។

២.៦ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់មូលប្បទានប័ត្រនៅតែជាទ្រព្យសម្បត្តិរបស់ធនាគារ ហើយបន្ទាប់ពីបិទគណនីចរន្ត រាល់មូលប្បទានប័ត្រដែលមិនទាន់បានប្រើប្រាស់ និងដែលចេញអោយខ្ញុំ/យើងខ្ញុំត្រូវតែប្រគល់ជូន ធនាគារវិញ ។

២.៧ ខ្ញុំ/យើងខ្ញុំត្រូវមានការប្រុងប្រយ័ត្នក្នុងការចេញមូលប្បទានប័ត្រ ដើម្បីការពារពីការក្លែងបន្លំ ហើយត្រូវមានការប្រុងប្រយ័ត្នគ្រប់ពេលដើម្បីការពារពីការលួច បន្លំ រឺប្រើប្រាស់នូវបែបបទមូលប្បទានប័ត្រ រឺសៀវភៅមូលប្បទានប័ត្រដែលចេញអោយខ្ញុំ/យើងខ្ញុំដោយគ្មានការអនុញ្ញាត ។ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា ខ្ញុំ/យើងខ្ញុំធានាអះអាងថា នៅមុនពេលចេញមូលប្បទានប័ត្រ ខ្ញុំ/យើងខ្ញុំត្រូវមានមូលនិធិគ្រប់គ្រាន់នៅក្នុងគណនីសំរាប់ចេញមូលប្បទានប័ត្រ ។ ក្នុងករណីដែលមានការខូចខាតបណ្តាលមកពីកំហុសរបស់ខ្ញុំ/យើងខ្ញុំ ដោយសារមិនបានប្រុងប្រយត្ន័ដូចបានកំណត់ខាងលើ រឺមិនធានាបាននូវមូលនិធិគ្រប់គ្រាន់នោះធនាគារត្រូវបានរួចផុតពីកាតព្វកិច្ច និង/រឺក៏ទទួលបានសំណងពេញលេញពីខ្ញុំ/យើងខ្ញុំចំពោះការខូចខាតដែលកើតឡើងដោយសារការក្លែងបន្លំ រឺលួច បន្លំ រឺការប្រើប្រាស់ដោយគ្មានការអនុញ្ញាត រឺភាពមិនគ្រប់គ្រាន់នៃមូលនិធិដែលធ្វើអោយមានការបដិសេធចោលនូវមូលប្បទានប័ត្រដែលបានចែងខាងលើ ។ ជាពិសេសនិងដោយមិនគិតពីលក្ខណៈទូទៅខាងដើម ខ្ញុំ/យើងខ្ញុំត្រូវ មានការប្រុងប្រយត្ន័លើករណីដូចតទៅ:

(ក) សិទ្ធិរក្សាទុក ត្រួតពិនិត្យ និងប្រើប្រាស់នូវបែបបទស្នើសុំមូលប្បទានប័ត្រ និងសៀវភៅមូលប្បទានប័ត្រ ហើយខ្ញុំ/យើងខ្ញុំត្រូវជូនដំណឹងដល់ធនាគារភ្លាមបន្ទាប់ពីដឹងពីការបាត់សៀវភៅ មូលប្បទានប័ត្រ រឺបែបបទស្នើសុំមូលប្បទានប័ត្រ ។

(ខ) ធានាអះអាងថារាល់មូលប្បទានប័ត្រដែលបានចេញរួចមិនត្រូវមានការបន្ថែម រឺកែប្រែឡើយ ហើយជាពិសេសត្រូវតែបំពេញអោយបានពេញលេញនូវរាល់ចន្លោះចំហ ។ រាល់ការកែប្រែលើមូលប្បទានប័ត្រ រួមទាំងមូលប្បទានប័ត្រដែលធ្វើឡើងដោយម៉ាស៊ីនលាយលក្ខណ៍អក្សរអេឡិចត្រូនិក រឺម៉ាស៊ីនបោះពុម្ពត្រូវតែមាន ហត្ថលេខាអមដោយបុគ្គលដែលបានទទួលបានសិទ្ធិតាមអាណត្តិ ដែលបានប្រគល់ជូនធនាគារ ហើយធនាគារមានឆន្ទានុសិទ្ធិ និងមិនមានការទទួលខុសត្រូវចំពោះការបដិសេធនូវមូលប្បទានប័ត្រដែលបានកែប្រែ ទោះបីជាមានចុះហត្ថលេខាអមដោយបុគ្គលដែលទទួលបានសិទ្ធិតាមអាណត្តិដែលបានប្រគល់ជូនធនាគារក៏ដោយ ។

(គ) ប្រសិនបើបែបបទមូលប្បទានប័ត្រ ត្រូវបានចុះហត្ថលេខាទុកជាមុន ទោះបីជាដោយបុគ្គលមួយ រូប រឺច្រើនរូបដែលទទួលបានសិទ្ធិតាមអាណត្តិដែលបានប្រគល់ជូនធនាគារ រឺត្រូវបានចុះហត្ថលេខា ដោយទុកចំហដោយខ្ញុំ/យើងខ្ញុំ ហើយត្រូវបានប្រគល់ជូនក្នុងគោលបំណងអនុញ្ញាតអោយបុគ្គលណាមួយធ្វើការផ្លាស់ប្តូរមូលប្បទានប័ត្រនេះទៅជាវិក្កយបត្រ រឺមូលប្បទានប័ត្រដែលមានសុពលភាព (ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីរូបិយាណត្តិ ឆ្នាំ១៩៤៩ ដែលត្រូវបានធ្វើវិសោធនកម្មជាប្រចាំ) បុគ្គលនោះត្រូវបានចាត់ទុកថា បានទទួលសិទ្ធិពេញលេញពីខ្ញុំ/យើងខ្ញុំ ក្នុងការបំពេញតួនាទីជំនួសខ្ញុំ/យើងខ្ញុំ ហើយខ្ញុំ/យើងខ្ញុំមិនអាចបដិសេធនូវមូលប្បទានប័ត្រណាដែលត្រូវបានបំពេញដោយមូលហេតុថាគ្មានការអនុញ្ញាតិពីខ្ញុំ/យើងខ្ញុំ រឺប្តឹងទាមទារសំណងអ្វីឡើយ បើសិនជាមានការ ខូចខាតកើតឡើង ។

(ឃ) ត្រូវពិនិត្យជាមុនថាតើ មានមូលនិធិគ្រប់គ្រាន់រឺទេមុនពេលចេញមូលប្បទានប័ត្រខាងលើ ។

### ៣. សេចក្តីអនុញ្ញាត និង សំណើ

ខ្ញុំ/យើងខ្ញុំ អនុញ្ញាត និងស្នើសុំអោយធនាគារគោរព និងអនុវត្តតាមរាល់មូលប្បទានប័ត្រ រូបិយាណត្តិ (Drafts) ការបញ្ជាអោយបង់ប្រាក់ (Order to pay) រូបិយាណត្តិ (Bills of Exchange) រឺលិខិតសន្យាផ្តល់ប្រាក់តាមកាលកំណត់ (Promissory Notes) ដែលត្រូវបានចេញ ចុះហត្ថលេខា ទទួលស្គាល់ ធារខ្នង ច្បាស់លាស់ រឺធ្វើឡើងក្នុងនាមខ្ញុំ/យើងខ្ញុំ រឺត្រូវបានផ្ញើរជូន រឺត្រូវបានបង់ប្រាក់ដោយធនាគារ ទោះបីជា គណនីរបស់ខ្ញុំ/ យើងខ្ញុំស្ថិតនៅជាឥណទាន រឺឥណពន្ធ រឺក្លាយជាឥណទានវិបារូបន៍ រឺករណីផ្សេងទៀតក៏ដោយ ។

### ៤. ឥណទានវិបារូបន៍ (Overdraft)

ខ្ញុំ/យើងខ្ញុំយល់ព្រមថា ក្នុងករណីដែលធនាគារអនុញ្ញាតអោយធ្វើឥណទានវិបារូបន៍ ខ្ញុំ/យើងខ្ញុំត្រូវ បង់ជូនធនាគារវិញនូវប្រាក់ដែលបានដកជាមុន ដោយយោងតាមឆន្ទានុសិទ្ធិរបស់ធនាគាររួមជាមួយនឹងការប្រាក់ និងកម្រៃជើងសារ ប័ណ្ណអប្បហារ និងកម្រៃធនាគារ ប្រសិនបើមាន ។ អត្រាការប្រាក់របស់ឥណទានវិបារូបន៍ត្រូវ បានកំណត់ជាប្រចាំដោយធនាគារ ហើយត្រូវបានគណនាលើប្រាក់ដែលបានធ្វើឥណទានវិបារូបន៍តាម មូលដ្ឋានប្រចាំថ្ងៃ ។ ប្រសិនបើការប្រាក់ទាំងនេះ រឺមួយផ្នែកមិនបានបង់ជូនធនាគារប្រចាំខែនោះទេ ប្រាក់ទាំងនេះត្រូវបានបូកបញ្ចូលជាមួយ (ក្នុងករណីដែលនៅតែមិនទាន់បង់) ប្រាក់ដើមដែលបានធ្វើឥណទានវិបារូបន៍ នៅពេលជំពាក់នោះ រឺឯការប្រាក់ត្រូវបន្ថែមពីលើនេះផងដែរ ។

## គ. លក្ខខណ្ឌទូទៅ

### ១. កម្រៃធនាគារ

ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមានសិទ្ធិយកកម្រៃលើសេវាដែលធនាគារបានផ្តល់អោយខ្ញុំ/យើងខ្ញុំតាម អត្រាមួយដែលធនាគារបានជូនដំណឹងជាប្រចាំមកខ្ញុំ/យើងខ្ញុំ រឺតាមអត្រាសមស្របណាមួយ ប្រសិនជាមិនមានការជូនដំណឹងនោះទេ ។ រាល់កម្រៃធនាគារដែលត្រូវដល់ពេលបង់ ត្រូវកាត់ចេញពីគណនីធនាគាររបស់ខ្ញុំ/ យើងខ្ញុំ (ដូចមានចែងនៅក្នុងប្រការ ១៦ ខាងក្រោម) ។

### ២. ការបង្កកគណនីធនាគារ

២.១ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមានសិទ្ធិដោយពុំចាំបាច់ផ្តល់ដំណឹងជាមុនដល់ខ្ញុំ/យើងខ្ញុំក្នុងការបញ្ឈប់សុពលភាព រឺបញ្ឈប់ប្រតិបត្តិការផ្សេងៗ រួមមានតែមិនកម្រិតត្រឹមការបង់ប្រាក់ជារូបិយវត្ថុ រឺមូលប្បទានប័ត្រ រឺលិខិតុបករណ៍នានា រឺអនុទ្ទេសអោយបង់ប្រាក់ចេញពីគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ និង/រឺ ការទទួលស្គាល់ និង/រឺការធ្វើបេឡានិច័យមូលប្បទានប័ត្ររូបិយវត្ថុ រឺលិខិតុបករណ៍ រឺអនុទ្ទេសនានាដើម្បីផ្តល់ប្រសិទ្ធិភាពដល់វិក្កយបត្រសម្រាប់បង់ប្រាក់ទៅក្នុងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ (បង្កកគណនីធនាគារ) ដោយយោងទៅតាម ករណីដូចតទៅនេះ:

(ក) នៅពេលដែលធនាគារបានទទួលការជូនដំណឹងថា ខ្ញុំ/យើងខ្ញុំ ស្ថិតនៅក្នុងស្ថានភាពក្ស័យធន និង/រឺ មានបណ្តឹងសុំរំលាយក្រុមហ៊ុន រឺមានការបង្ហាញករណីក្ស័យធនប្រឆាំងនឹងខ្ញុំ/យើងខ្ញុំ រឺអភិបាលម្នាក់ រឺច្រើននាក់របស់យើងខ្ញុំត្រូវបានវិនិច្ឆ័យថា ក្ស័យធន ហើយអ្នកទាំងនោះជាហត្ថលេខីលើគណនីធនាគារ (បញ្ហា អសាធនភាព) ។

(ខ) ក្រោយពេលធនាគារបានទទួលការជូនដំណឹងទាក់ទងនឹងបណ្តឹងជំទាស់ រឺប្តឹងបក រឺបណ្តឹងជំលោះណាមួយដោយសហកម្មសិទ្ធិករ អភិបាល រឺម្ចាស់ភាគហ៊ុន រឺអ្នកកាន់កាប់គណនីរួមផ្សេងទៀត រឺដោយបុគ្គល ដែលត្រូវចោទប្រកាន់ថា ជាសហកម្មសិទ្ធិករ អភិបាល រឺម្ចាស់ភាគហ៊ុនទាក់ទងទៅនឹងគណនី ដែលជាគណនីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ រឺក្រុមហ៊ុនដែលជាប់ទាក់ទងទៅនឹងប្រតិលាភ រឺតុល្យការនៃគណនីធនាគារ រឺប្រតិបត្តិការរបស់គណនីធនាគារនេះ រឺអាណត្តិ (បញ្ហាផ្ទៃក្នុងរបស់អតិថិជន) ។

(គ) ក្រោយពេលធនាគារបានទទួលការជូនដំណឹងទាក់ទងទៅនឹងបណ្តឹងជំទាស់ រឺប្តឹងបក រឺបណ្តឹង ជំលោះ ដោយអ្នកកាន់កាប់គណនីរួមម្នាក់ពាក់ព័ន្ធនឹងគណនីរួមណាមួយកាន់កាប់ដោយយើងខ្ញុំ ដែលជាប់ទាក់ទងទៅនឹងប្រតិលាភ រឺអាណត្តិ រឺប្រតិបត្តិការរបស់ធនាគាររួមនេះ ។

(ឃ) ធនាគារបានទទួលការជូនដំណឹង និងស្នើសុំដោយអាជ្ញាធរណាមួយ រួមមានតែមិនកម្រិតត្រឹម ធនាគារជាតិនៃកម្ពុជា នគរបាល រឺស្ថាប័ននិយ័តកម្មដើម្បីទប់ស្កាត់ការបំពេញប្រតិបត្តិការស្ថិតនៅក្រោមគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំដូចដែលបានចែងខាងដើម ដោយមិនគិតថាតើអាជ្ញាធរទាំងនោះមានសិទ្ធិត្រឹមត្រូវតាម ច្បាប់ក្នុងការស្នើសុំទៅធនាគារ (សេចក្តីបង្គាប់របស់អាជ្ញាធរ) និង

(ង) ធនាគារ នគរបាល រឺស្ថាប័ននិយ័តកម្មដឹកនាំការស៊ើបអង្កេតទៅលើប្រតិបត្តិការខុសច្បាប់ ដែល កើតមានឡើងលើគណនីធនាគារ រឺការប្រើប្រាស់ខុស រឺភាពសង្ស័យលើការប្រើប្រាស់ខុសនូវគណនី ធនាគារ រឺប្រតិបត្តិការក្លែងបន្លំទាក់ទងទៅនឹងគណនីធនាគារ រួមមានតែមិនកម្រិតត្រឹម ការបញ្ញើមូលប្បទានប័ត្រដែលខ្ញុំ/យើងខ្ញុំមិនមានសិទ្ធិ រឺយោងតាមរបាយការណ៍របស់នគរបាលប្រឆាំងនឹង ខ្ញុំ/យើងខ្ញុំ រឺ/និងទាក់ទងទៅនឹងគណនីធនាគារដោយធនាគារ រឺបុគ្គលណាមួយផ្សេងទៀត ។

២.២ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ការបង្កកគណនីធនាគារដូចដែលបានចែងខាងលើ ត្រូវបញ្ឈប់ រឺលើកលែងចោល ក្នុងករណីដូចតទៅ:

(ក) ចំពោះបញ្ហាអសាធនភាព ខ្ញុំ/យើងខ្ញុំត្រូវបង្ហាញអោយធនាគារត្រឹមកម្រិតដែលអាចទទួលយក បាននូវភស្តុតាងសមស្របមួយថា រាល់បណ្តឹងសម្រាប់រំលាយ ក្រុមហ៊ុន រឺក្ស័យធនត្រូវបានដក រឺលើកលែងចោល រឺពាក្យសុំអោយទុកចោលបញ្ហាក្ស័យធនត្រូវបានបំពេញ រឺនៅពេលដែលអភិបាលម្នាក់ រឺច្រើននាក់របស់យើងខ្ញុំ ត្រូវបាន វិនិច្ឆ័យថាក្ស័យធន ធនាគារបានទទួលនូវអាណត្តិថ្មីក្នុងការផ្លាស់ប្តូរហត្ថលេខីរបស់គណនីធនាគាររបស់យើងខ្ញុំ រឺ ប្រសិនបើធនាគារទទួលបាននូវបញ្ជាត្រឹមត្រូវពីតុលាការសំរេចពីការលើកលែងការបង្កកគណនី ។

(ខ) ចំពោះបញ្ហាផ្ទៃក្នុងរបស់អតិថិជន រឺគណនីរួមដែលមានចែងនៅក្នុងប្រការ ២.១(ខ) និង(គ) ខាងលើ គួរត្រូវបានដោះស្រាយរវាងភាគីដែលពាក់ព័ន្ធទាំងអស់ ហើយសេចក្តីថ្លែងការណ៍ជា លាយលក្ខណ៍អក្សរ រឺសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល (អាស្រ័យតាមករណីនីមួយៗ) ត្រូវចុះហត្ថលេខាដោយភាគីទាំងអស់ ស្របទៅតាមលក្ខន្តិកៈក្រុមហ៊ុន សំរាប់ស្នើសុំអោយធនាគារ លើក លែងការបង្កកគណនីធនាគារ រឺក្នុងករណីដែលធនាគារបានទទួលបញ្ជាពីតុលាការសំរេចលើកលែងការបង្កកគណនីធនាគារ ។

(គ) ចំពោះសេចក្តីបង្គាប់របស់អាជ្ញាធរ នៅពេលដែលធនាគារបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអាជ្ញាធរអោយលើកលែងការបង្កកគណនីធនាគារ រឺទទួលបានបញ្ជាពីតុលាការអោយ លើកលែងការបង្កកគណនីធនាគារ ។ និង

(ឃ) ចំពោះការស៊ើបអង្កេតដោយធនាគារ នគរបាល រឺអាជ្ញាធរពាក់ព័ន្ធ គឺនៅពេលធនាគារយល់ថា មិនចាំបាច់បន្តការស៊ើបអង្កេត រឺធនាគារបានទទួលលិខិតបញ្ជាក់ពីនគរបាល រឺអាជ្ញាធរពាក់ព័ន្ធថា ការស៊ើបអង្កេតមិនត្រូវបានបន្តនោះគណនីធនាគារនឹងមិនត្រូវជាប់ទាក់ទងនឹងការស៊ើបអង្កេតបន្តទៀតឡើយ ។

២.៣ ការបង្កកគណនីធនាគារយោងទៅតាមលក្ខខណ្ឌទាំងនេះ រួមទាំងសកម្មភាពដែលធ្វើឡើងដោយធនាគារ ដូចជា ការប្រគល់មកវិញនូវមូលប្បទានប័ត្រ រឺលិខិតុបករណ៍ផ្សេងទៀត ទោះបីជាត្រូវបានធ្វើបញ្ញើសម្រាប់បេឡានិច័យ រឺការបង់ប្រាក់ដូចដែលមានចែងខាងលើ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមិនទទួលខុសត្រូវលើការខាតបង់ ការខូចខាត ការចំណាយ សោហ៊ុយ រឺកម្រៃដែលត្រូវបានទាមទារពីធនាគារ រឺដែលកើតមានឡើងនៅធនាគារ (រួមមានកម្រៃជាមូលដ្ឋានលើសេវាកម្មមេធាវី និងរបស់អតិថិជន) ព្រមជាមួយគ្នានេះផងដែរ ខ្ញុំ/យើងខ្ញុំ យល់ព្រមសងសំណងពេញលេញជូនធនាគារនូវរាល់បណ្តឹងលើការខូចខាត ចំណាយផ្សេងៗ សោហ៊ុយ កម្រៃដែលធ្វើឡើងប្រឆាំងនឹងធនាគារ រឺភាគីដទៃទៀត ។

២.៤ ខ្ញុំ/យើងខ្ញុំយល់ព្រមថា នៅពេលមានបណ្តឹងតទល់នឹងធនាគារ រឺធនាគារក្លាយជាភាគីនៃរឿងក្តីណាមួយ ដែលកើតឡើងពីបណ្តឹងរបស់ធនាគារសម្រាប់បង្កកគណនីធនាគារ រឺក្នុងករណីធនាគារចាប់ផ្តើមដាក់ពាក្យ បណ្តឹងប្រឆាំងនឹងភាគីណាមួយរួមទាំងខ្ញុំ/យើងខ្ញុំនៅមុនពេល រឺក្រោយពេលបង្កកគណនីសម្រាប់សេចក្តីលើកលែង រឺប្រកាសរបស់តុលាការ រាល់ពិន័យលើការខូចខាត ការខាតបង់ បណ្តឹងទាមទារ ចំណាយ សោហ៊ុយ រឺកម្រៃផ្សេងៗ (ចំណាយផ្លូវច្បាប់ រឺចំណាយផ្សេងទៀតរួមមានកម្រៃជាមូលដ្ឋានលើសេវាកម្មមេធាវី និងរបស់អតិថិជន) ដែលធ្វើឡើងប្រឆាំងនឹងធនាគារ រឺចំណាយដែលទទួលរងដោយធនាគារ នោះខ្ញុំ/យើងខ្ញុំទទួលសងសំណងជូនធនាគារវិញ ។

២.៥ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់មូលប្បទានប័ត្រ និងលិខិតុបករណ៍នានាដែលត្រូវបានប្រគល់មកវិញដោយ ធនាគារ ទោះបីសម្រាប់ការបង់ប្រាក់ រឺបេឡានិច័យដែលបណ្តាលមកពីការបង្កកគណនីធនាគារ ត្រូវតែមាន ឬ អមដោយកំណត់បង្ហាញសមរម្យដែលអាចទទួលយកបានដោយធនាគារ ហើយខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា រាល់សកម្មភាពដែលធ្វើដោយធនាគារយោងតាមប្រការ ២ នៃលក្ខខណ្ឌនេះ ធនាគារមិនទទួលខុសត្រូវចំពោះ ការខូចខាត ការខាតបង់ ចំណាយ សោហ៊ុយ រឺកម្រៃនានាដែលកើតឡើងពីបណ្តឹងប្រឆាំងនឹងធនាគារ ទោះបីជា ខ្ញុំ/យើងខ្ញុំ មិនបានទទួលការជូនដំណឹងដូចដែលមានចែងនៅក្នុងប្រការ ២ ខាងលើ រឺដោយមូលហេតុថា ការជូនដំណឹងនេះមានលក្ខណៈមិនប្រក្រតី គ្មានសុពលភាព មានកំហុស ជាមោឃៈ គ្មានប្រសិទ្ធិភាព រឺដោយមូលហេតុ រឺមូលដ្ឋានផ្សេងទៀតក៏ដោយ ។

## ៣. ការផ្លាស់ប្តូរអាសយដ្ឋាន ហត្ថលេខា រឺករណីផ្សេងទៀត

ខ្ញុំ/យើងខ្ញុំយល់ព្រមជូនដំណឹងទៅធនាគារជាលាយលក្ខណ៍អក្សរ រាល់ការផ្លាស់ប្តូរអាសយដ្ឋាន ហត្ថលេខា រឺករណីផ្សេងទៀតដែលត្រូវតែជំរាបជូនធនាគារ ។ រាល់ការទាក់ទងរួមទាំងសេវាផ្លូវច្បាប់ផ្សេងៗ ដែលផ្ញើរតាមប្រៃសណីយ៍ រឺទុកនៅអាសយដ្ឋានរបស់ខ្ញុំ/យើងខ្ញុំដែលបានចុះបញ្ជីចុងក្រោយជាមួយធនាគារ ត្រូវបានចាត់ទុកថា ខ្ញុំ/យើងខ្ញុំបានទទួលលិខិតជូនដំណឹងនោះយ៉ាងត្រឹមត្រូវ ។

## ៤. សិទ្ធិរបស់ធនាគារក្នុងការមិនធ្វើបេឡានិច័យមូលប្បទានប័ត្រ

៤.១ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគាររក្សាសិទ្ធិ:

(ក) មិនធ្វើបេឡានិច័យមូលប្បទានប័ត្រដែលត្រូវបានឆូត "គណនីអត្ថាគាហក" រឺ "A/Cអត្ថាគាហក" ដោយមាន រឺ មិនមានពាក្យ "តែប៉ុណ្ណោះ" ហើយដែលធ្វើឡើងដើម្បីប្រយោជន៍តតិយជនដែលចេញដោយ ខ្ញុំ/យើងខ្ញុំ សម្រាប់គណនីធនាគាររបស់ ខ្ញុំ/យើងខ្ញុំ ។

(ខ) មិនធ្វើបេឡានិច័យមូលប្បទានប័ត្រដែលត្រូវបានធ្វើឡើងដោយមានឈ្មោះអត្ថាគាហកពីរ រឺ ច្រើននាក់ និងមានពាក្យ "និង" នៅចន្លោះឈ្មោះពីរ រឺច្រើននាក់នៅក្នុងគណនីផ្ទាល់ខ្លួន ដែលជាកម្មសិទ្ធិផ្ទាល់របស់អត្ថាគាហកម្នាក់ក្នុងចំណោមអត្ថាគាហកទាំងអស់ ។ ដើម្បីជៀសវាងភាពមន្ទិលសង្ស័យ ធនាគារអាចធ្វើបេឡានិច័យមូលប្បទានប័ត្រនេះចូលទៅក្នុងគណនីរួមរបស់អត្ថាគាហកទាំងអស់គ្នា ដែលបានចែងនៅក្នុងមូលប្បទានប័ត្រ ។

(គ) មិនធ្វើបេឡានិច័យមូលប្បទានប័ត្រដែលបានធ្វើឡើង ដោយមានឈ្មោះពីរ រឺច្រើននាក់ និងមានពាក្យ "និង/ឬ" នៅចន្លោះឈ្មោះពីរ រឺច្រើននាក់ នៅក្នុងគណនីរួមណាមួយរបស់អត្ថាគាហកទាំងអស់ រឺគណនីផ្ទាល់ខ្លួនដែលជាកម្មសិទ្ធិផ្ទាល់របស់អត្ថាគាហកម្នាក់ក្នុងចំណោមអត្ថាគាហកទាំងអស់ ។

(ឃ) មិនធ្វើបេឡានិច័យមូលប្បទានប័ត្រដែលធ្វើឡើងដោយឈ្មោះពីរ រឺច្រើននាក់ ជាមួយពាក្យ "រឺ" នៅចន្លោះឈ្មោះពីរ រឺច្រើននាក់នៅក្នុងគណនីផ្ទាល់ខ្លួនណាមួយរបស់អត្ថាគាហក រឺនៅក្នុងគណនីរួមណាមួយដែលគ្រប់គ្រងដោយអត្ថាគាហកទាំងអស់ រឺអត្ថាគាហកម្នាក់ក្នុងចំណោមអត្ថាគាហកទាំងអស់ជាមួយ នឹងបុគ្គលផ្សេងទៀត ។

(ង) មិនធ្វើបេឡានិច័យមូលប្បទានប័ត្រសម្រាប់មូលហេតុណាមួយតាមឆន្ទានុសិទ្ធិរបស់ខ្លួនដែល ធនាគារ យល់ថាត្រឹមត្រូវ ដោយពុំចាំបាច់បង្ហាញមូលហេតុអ្វីមួយឡើយ ។

## ៥. ដែនកំណត់នៃការទទួលខុសត្រូវ

៥.១ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារនឹងមិនទទួលខុសត្រូវ ហើយខ្ញុំ/យើងខ្ញុំត្រូវផ្តល់សំណងពេញលេញជូន ធនាគារ និង មិនធ្វើអោយធនាគារទទួលរងនូវការខូចខាត ចេញសោហ៊ុយ រឺការចំណាយផ្សេងៗ ដែលអាចកើត ឡើងចំពោះខ្ញុំ/យើងខ្ញុំ រឺដោយធនាគារដែលទាក់ទងទៅនឹងគណនីធនាគារណាមួយ រឺគណនីទាំងអស់ រឺរាល់ការអនុវត្តន៍ ដោយធនាគារនូវលិខិតុបករណ៍ផ្សេងៗ រឺគណនីធនាគារណាមួយ រឺគណនីទាំងអស់របស់ខ្ញុំ/យើងខ្ញុំ រឺផ្នែកណាមួយដែលត្រូវបានកាត់បន្ថយ រឺ បង្កកដោយរដ្ឋាភិបាល រឺមន្ត្រីអាជ្ញាធរណាមួយឡើយ ។

៥.២ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា នៅពេលដែលធនាគារត្រូវទទួលខុសត្រូវ រឺតាមការស្នើសុំរបស់ខ្ញុំ/យើងខ្ញុំ ចំពោះមូលនិធិ មូលប័ត្រ (Securities) រូបិយវត្ថុ ដែលជាឥណទានរបស់ខ្ញុំ/យើងខ្ញុំ និងវត្ថុមានតម្លៃផ្សេងទៀតដែលបានដាក់បញ្ញើជាមួយនឹងធនាគារ រឺនឹងត្រូវបានដាក់បញ្ញើនៅធនាគារ (ទោះបីត្រូវបានដាក់បញ្ញើ តាមរយៈ ការដាក់ធានា ទូដែកសុវត្ថិភាព រឺក្នុងគោលបំណងពិសេសណាមួយផ្សេងទៀត) ដែលជាកម្មសិទ្ធិរបស់ខ្ញុំ/យើងខ្ញុំ ធនាគារត្រូវមានចំណងទៅនឹងមូលនិធិ មូលប័ត្រ រូបិយវត្ថុ ដូចដែលមានចែងខាងដើម ដែលជាឥណទានរបស់ ខ្ញុំ/យើងខ្ញុំ និងវត្ថុមានតម្លៃផ្សេងទៀតដែលបានដាក់បញ្ញើជាមួយធនាគារ ហើយធនាគារមាន សិទ្ធិរក្សាទុកនូវមូលនិធិ

មូលប័ត្រ រូបិយវត្ថុ និង វត្ថុមានតម្លៃផ្សេងទៀត រឺផ្នែកណាមួយ ព្រមទាំងបដិសេធនូវមូលប្បទានប័ត្រ ដែលបានចេញរួចហើយ រឺរាល់ការដកប្រាក់ដែលធ្វើឡើងដោយខ្ញុំ/យើងខ្ញុំ រហូតដល់ពេលដែល រាល់កាតព្វកិច្ចទាំងអស់ត្រូវបានដោះស្រាយរួចរាល់ ។

៥.៣ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមិនទទួលខុសត្រូវលើរាល់ការខាតបង់ប្រាក់ចំណេញ ការខាតបង់ខាង ពាណិជ្ជកម្ម ការខាតបង់ក្នុងការប្រើប្រាស់ ខាតបង់នូវ កេរ្តិ៍ឈ្មោះខាងជំនួញ បាត់បង់ការសន្សំ រឺក៏ការខូចខាត ផ្សេងទៀតដែលជាផលវិបាក ជាពិសេស ជាយថាហេតុ ដោយផ្ទាល់ រឺដំងឺចិត្ត ដែលរងគ្រោះដោយខ្ញុំ/យើងខ្ញុំ ដោយសារការពន្យាពេលអនុវត្ត រឺមិនអនុវត្តកាតព្វកិច្ចណាមួយរបស់ធនាគារ ទោះបីជាកើតឡើងដោយសារ តែការធ្វេសប្រហែស រឺរំលោភទៅលើលក្ខខណ្ឌទាំងនេះ រឺតាមរយៈអ្វីក៏ដោយ ។ ដោយមិនគិតពីអ្វីដែលផ្ទុយនឹងលក្ខខណ្ឌចែងខាងលើ ការទទួលខុសត្រូវទាំងស្រុងរបស់ធនាគារ ត្រូវបានកំណត់ ត្រឹមតែការខូចខាតជាក់ស្តែងដែល ខ្ញុំ/យើងខ្ញុំទទួលរង (ក្នុងករណីដែលមានឯកសារភស្តុតាងត្រឹមត្រូវ បានដាក់ជូនធនាគារដោយខ្ញុំ/យើងខ្ញុំ) ប៉ុន្តែការទទួលខុសត្រូវនេះ មិនអាចលើសពី ៥០០ RM រឺមានតម្លៃស្មើនឹងប្រាក់ ដុល្លារសហរដ្ឋអាមេរិក រឺប្រាក់រៀលសម្រាប់រាល់បណ្តឹងទាមទារទាំងអស់ ។

៥.៤ ខ្ញុំ/យើងខ្ញុំយល់ព្រមផ្តល់សំណងជូនធនាគារនូវរាល់បណ្តឹងទាមទារ ដែលធ្វើឡើងប្រឆាំងនឹងធនាគារ និង រាល់ការផាកពិន័យ ការខូចខាត ការទាមទារ ការខាតបង់ សោហ៊ុយ និងចំណាយផ្សេងទៀត (ចំណាយផ្លូវច្បាប់ រឺចំណាយផ្សេងទៀតរួមមានកម្រៃជាមូលដ្ឋានលើសេវាកម្មមេធាវី និងរបស់អតិថិជន) ដែលធនាគារបានទទួល ដូចជា:

(ក) ដោយសារធនាគារដកហូតសុពលភាពរបស់អាណត្តិណាមួយដែលខ្ញុំ/យើងខ្ញុំបានស្នើសុំ

(ខ) ដាយសារធនាគារបានពង្រឹងសិទ្ធិប្រឆាំងនឹងខ្ញុំ/យើងខ្ញុំ ហើយ

(គ) ដោយសារធនាគារអនុវត្តតាមសេចក្តីសំរេចរបស់តុលាការ រឺបញ្ជារបស់តុលាការ រឺក្រិត្យច្បាប់ រឺបទបញ្ជា រឺ សេចក្តីបង្គាប់បញ្ជា ទោះមាន រឺគ្មានអំណាចផ្លូវច្បាប់ ដែលចេញដោយអាជ្ញាធរស្របច្បាប់ ណាមួយ រឺក្រុមជំនុំជំរះ ដែលកើតឡើងដោយសារបណ្តឹងតុលាការ រឺនីតិវិធីតុលាការ រឺបណ្តូលមកពីបណ្តឹងនីតិវិធី រឺបណ្តឹងណាមួយ ដែលមិនមែនជាបណ្តឹងតុលាការ ហើយដែលអាចអនុវត្តដោយផ្ទាល់ ចំពោះខ្ញុំ/យើងខ្ញុំ រឺដែលជាប់ទាក់ទងទៅនឹង រឺ/និងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ រឺគណនីណាមួយរបស់ខ្ញុំ/យើងខ្ញុំ ដែលរក្សាទុកដោយធនាគារ រឺរាល់ព័ត៌មានពិសេស ដែលរក្សាទុកនៅក្នុងគណនី ដែលបានចែងខាងលើ ។

៥.៥ បន្ថែមលើវិធានការទាំងឡាយដែលមានចែងក្នុងប្រការនេះ ខ្ញុំ/យើងខ្ញុំយល់ព្រមថា វិញ្ញាបនបត្រណាមួយ ដែលចេញដោយនាយកគ្រប់គ្រង រឺបុគ្គលិកណាម្នាក់របស់ធនាគារដើម្បីបញ្ជាក់ថាចំនួនទឹកប្រាក់សម្រាប់សំណងនេះ នឹងត្រូវបានចាត់ទុកថាជាចុងក្រោយ ចងភ្ជាប់ និងដាច់ស្រេចសម្រាប់ខ្ញុំ/យើងខ្ញុំ។ ខ្ញុំ/យើងខ្ញុំយល់ព្រមថា បន្ថែមលើសពីសិទ្ធិផ្សេងទៀតដែលអាចប្រឆាំងនឹងខ្ញុំ/យើងខ្ញុំ ធនាគារមានសិទ្ធិធ្វើឥណពន្ធ រឺកាត់ចេញនូវចំនួនប្រាក់ដែលចែងខាង លើពីគណនីធនាគារដោយមិនបាច់ផ្តល់ដំណឹងអោយខ្ញុំ/យើងខ្ញុំជាមុនឡើយ ។

៥.៦ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា ធនាគារមិនទទួលខុសត្រូវឡើយចំពោះការខូចខាត ការខាតបង់ ទំនាស់ រឺការខាតបង់កេរ្តិ៍ឈ្មោះ ដោយសារ ខ្ញុំ/យើងខ្ញុំ ដោយមូលហេតុយឺតយ៉ាវក្នុងការអនុវត្ត រឺមិនអនុវត្តកាតព្វកិច្ចណាមួយរបស់ខ្ញុំ/យើងខ្ញុំចំពោះធនាគារ និងដោយមូលហេតុណាមួយដែលហួសពីការគ្រប់គ្រង ដោយសមហេតុផលរបស់ធនាគារ តែមិនកម្រិតត្រឹមមូលហេតុដូចជា ប្រពន្ធ័កុំព្យូទ័រ អេឡិចត្រូនិច រឺអគ្គីសនីដំណើរការមិនល្អ ខូចខាត រឺបង្អាក់ ការខកខានមិនផ្តល់ រឺការខកខានផ្តល់នូវអគ្គីសនី រឺចរន្តក្នុងរយៈពេលណាមួយ ។

## ៦. សិទ្ធិក្នុងការទូទាត់

ខ្ញុំ/យើងខ្ញុំយល់ព្រមថា បន្ថែមលើចំណងទូទៅ រឺសិទ្ធិប្រហាក់ប្រហែលផ្សេងទៀត ដែលធនាគារមានក្នុងនាមជាធនាគារិក ធនាគារមានសិទ្ធិតាមច្បាប់ និងគ្រប់ពេលវេលា ដោយពុំចាំបាច់ផ្តល់ដំណឹងជាមុន ក្នុងការ ដាក់បញ្ចូលរឺបង្រួមគ្នានូវរាល់គណនីធនាគារ រឺគណនីណាមួយ និងបំណុលចំពោះធនាគារ និងការទូទាត់ រឺការផ្ទេរនូវចំនួនទឹកប្រាក់ដែលជាឥណទានរបស់គណនីធនាគារណាមួយ រឺទាំងអស់ដើម្បីជំរះរាល់បំណុលរបស់ ខ្ញុំ/យើងខ្ញុំជូនធនាគារ ទោះបីបំណុលទាំងនេះជាបំណុលចំបង បន្ទាប់បន្សំ រឺដាច់ពីគ្នា រឺរួមគ្នាក៏ដោយ ។ លើសពីនេះ ទោះបីខ្ញុំ/យើងខ្ញុំអាចនឹងមានបំណុលដែលកើតឡើងជាយថាហេតុ រឺកើតឡើងនាពេលអនាគត រាល់ការ ទទួលខុសត្រូវរបស់ខ្ញុំ/យើងខ្ញុំក្នុងការបង់នូវចំនួនទឹកប្រាក់ពីឥណទាននៅក្នុងគណនីធនាគារណាមួយរបស់ខ្ញុំ/យើងខ្ញុំចំពោះបំណុលទាំងនោះ នឹងត្រូវបានពន្យាពេលរហូតដល់មានការកើតឡើងនូវហេតុការណ៍ជាយថាហេតុ រឺនៅពេលអនាគតនោះ ។

## ៧. ការបិទគណនីធនាគារ

ខ្ញុំ/យើងខ្ញុំយល់ព្រមអោយ ធនាគាររក្សាសិទ្ធិក្នុងការបិទគណនីធនាគារ ដោយត្រូវជូនដំណឹងក្នុងរយៈពេល ១៤ ថ្ងៃ តែធនាគារមិនចាំបាច់បញ្ជាក់ពីមូលហេតុនៃការបិទនោះទេ ។

## ៨. គណនីធនាគារដែលមានឈ្មោះរួម "គណនីរួម"

៨.១ បន្ថែមទៅលើលក្ខខណ្ឌដែលមានចែងនៅក្នុងលក្ខខណ្ឌទាំងនេះ ខ្ញុំ/យើងខ្ញុំយល់ព្រមគោរពតាមលក្ខខណ្ឌ គណនីរួមដូចតទៅ :

(ក) ក្នុងករណីដែលខ្ញុំ/យើងខ្ញុំ បើកគណនីរួមជាមួយធនាគារ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារអាចប្រមូលឥណទានទៅក្នុងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ មូលប្បទានបត្រ័ និងលិខិតុបករណ៏ផ្សេងៗ ដែលជាកម្មសិទ្ធិ រឺដែលត្រូវបង់អោយនរណាម្នាក់ក្នុងចំណោមពួកយើង និងគោរពតាមរាល់ការស្នើសុំសម្រាប់ដកប្រាក់/ឥណពន្ធ នៃរូបិយវត្ថុទាំងឡាយដែលជាឥណទានរបស់គណនីរួមដែលត្រូវបានផ្តល់អោយ រឺទាក់ទងទៅនឹងគណនីរួមខាងលើ ។ ដើម្បីជៀសវាងមន្ទិលសង្ស័យ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមានសិទ្ធិមិនធ្វើបេឡានិច័យមូលប្បទានបត្រ័ ដែលធ្វើឡើងក្នុងនាមពួកយើង ដោយមានពាក្យ (១)"និង/រឺ"និង(២)"រឺក៏" ដាក់នៅចន្លោះឈ្មោះរបស់ពួកយើង នៅក្នុងគណនីរួមណាមួយដែលកាន់កាប់ ដោយពួកយើង ។

(ខ) ក្នុងករណី នរណាម្នាក់ រឺទាំងអស់គ្នា ទទួលមរណៈភាព រឺរីកលចរិក នោះសមតុល្យឥណទាន របស់គណនីរួម ត្រូវបានបង់ជូនអ្នកនៅរស់ យោងទៅតាមច្បាប់ ហើយធនាគារត្រូវទទួលបាននូវសំណង ពីអ្នកនៅរស់ប្រឆាំងនូវរាល់បណ្តឹងដែលអាចធ្វើឡើងប្រឆាំងនឹងធនាគារ បន្ទាប់ពីធនាគារបានបង់ប្រាក់ទាំងនោះទៅអោយ អ្នកនៅរស់ហើយ ។

(គ) យោងតាមសិទ្ធិរបស់ធនាគារដែលមានចែងនៅប្រការ គ ២.១ និង២.២ ខាងលើ ក្នុងករណី បណ្តឹងស្តីពីក្ស័យធន រឺដីកាបញ្ជាក្ស័យធនដែលធ្វើឡើងប្រឆាំងនឹងនរណាម្នាក់ រឺយើងទាំង២នាក់ ធនាគារតាមការស្នើសុំរបស់នរណាម្នាក់ក្នុងចំណោមខ្ញុំ រឺយើងខ្ញុំទាំងអស់គ្នាថា ខ្ញុំ/យើងខ្ញុំដែលជាភាគីគ្មានកំហុស អនុញ្ញាតអោយខ្ញុំ/យើងខ្ញុំ ដោយយោងតាមឆន្ទានុសិទ្ធិរបស់ធនាគារ ធ្វើការដកប្រាក់ចេញពីគណនីរួមនូវចំនួនទឹកប្រាក់មួយដែលត្រូវស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់ធនាគារផងដែរ ។

(ឃ) ក្នុងករណីដែលនរណាម្នាក់ អ្នកខ្លះក្នុងចំណោមពួកយើង រឺគ្មាននរណាម្នាក់ក្នុងចំណោមពួកយើង ត្រូវបានអនុញ្ញាតធ្វើប្រតិបត្តិការលើគណនីរួមនេះ អាជ្ញាធរដែលទទួលបានការអនុញ្ញាតចំពោះ ហត្ថលេខីប្រតិស្រុតក្នុងការធ្វើប្រតិបត្តិការគណនីរួម ត្រូវបានចាត់ទុកថា បានរួមបញ្ចូលដោយគ្មានការកំណត់នូវករណីដូច តទៅ:

(១) ការដកប្រាក់ រឺឥណពន្ធសម្រាប់ទឹកប្រាក់ដែលជាឥណទានរបស់គណនីរួម ។

(២) បន្ត រឺបិទគណនីរួម ។

(៣) ប្រើប្រាស់រាល់កាតសម្រាប់ម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ និង លេខបណ្ណ័សំគាល់ខ្លួន សម្រាប់គណនីរួមនេះ ។

(៤) ប្រើរាល់មធ្យោបាយផ្សេងៗផ្តល់ដោយធនាគារ ដើម្បីបង់ថ្លៃវិក្កយបត្រ រឺផ្ទេរមូលនិធិពី គណនីរួម ។

(៥) ប្រើសេវាអេឡិចត្រូនិចណាមួយម្តងម្កាល ដែលផ្តល់ដោយធនាគារយោងតាមលក្ខខណ្ឌ និង ការបង់កម្រៃ សោហ៊ុយ និងចំណាយផ្សេងៗទាក់ទងទៅនឹងគណនីរួម ។

(៦) ផ្តល់នូវអនុទ្ទេសអចិន្ត្រៃយ៍ទាំងឡាយ ដែលមានសម្រាប់ការបង់ប្រាក់ទាំងអស់ទាក់ទងទៅនឹង គណនីរួម

(៧) ផ្តល់ប្រាក់សំណងជាលាយលក្ខណ៏អក្សរ ដែលទាមទារដោយធនាគារទាក់ទងទៅនឹង ប្រតិបត្តិការគណនីរួម រឺ អ្វីដូចដែលបានចែងខាងដើម ។

(៨) និងជាទូទៅ អំណាចក្នុងការអនុវត្ត លុបចោល កែប្រែ រឺធ្វើអ្វីៗទាំងអស់ដែលទាក់ទងទៅនឹង បញ្ហាដែលបានចែងពីខាងដើម ។

Maybank

៨.២ ប្រសិនបើធនាគារមានមន្ទិលសង្ស័យចំពោះអនុទ្ទេសណាមួយធ្វើឡើងដោយនរណាម្នាក់ រឺច្រើននាក់របស់ យើងខ្ញុំទាក់ទងនឹងប្រតិបត្តិការគណនីរួមនេះ ធនាគារមានសិទ្ធិប្រសិនបើចាំបាច់ទាមទារនូវលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរពីយើងខ្ញុំទាំងអស់គ្នា មុនពេលអនុវត្តតាមអនុទ្ទេសដោយមិនចាំបាច់ទទួលខុសត្រូវចំពោះយើងខ្ញុំ ដោយធ្វើដូច្នេះឡើយ ។

## ៩. គណនីធនាគារត្រូវបានចុះបញ្ជីជាគណនីសហកម្មសិទ្ធិ "គណនីសហកម្មសិទ្ធិ"

៩.១ បន្ថែមលើលក្ខខណ្ឌផ្សេងទៀតដែលមានចែងក្នុងលក្ខខណ្ឌទាំងនេះ យើងខ្ញុំយល់ព្រមគោរពតាមលក្ខខណ្ឌ ចងភ្ជាប់ដូចតទៅ :

(ក) ខ្ញុំ/យើងខ្ញុំយល់ព្រមថា ខ្ញុំ/យើងខ្ញុំត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវរាល់បំណុលគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ និងរាល់វិធានគ្រប់គ្រងគណនី សហកម្មសិទ្ធិ និងសេវាផ្សេងៗ ដោយចងភ្ជាប់ខ្ញុំ/យើងខ្ញុំដែលជាសហកម្មសិទ្ធិរួមគ្នា និងដាច់ដោយឡែកពីគ្នា ។

(ខ) អនុទ្ទេស និងអាណត្តិដែលផ្តល់សម្រាប់ប្រតិបត្តិការគណនីសហកម្មសិទ្ធិរបស់យើងខ្ញុំ នឹងមាន សុពលភាពរហូតត្រូវបានដកចេញដោយលិខិតលាយលក្ខណ៍អក្សរ និងជំនួសដោយអនុទ្ទេស និងអាណត្តិថ្មី ហើយនឹងអនុវត្តតាមនេះ ទោះបីមានការផ្លាស់ប្តូរសមាជិករបស់ក្រុមហ៊ុនដោយមូលហេតុមរណៈភាព ក្ស័យធន ចូលនិវត្តន៍ រឺករណីផ្សេងទៀត រឺការទទួលចូលនូវសហកម្មសិទ្ធិករថ្មី រឺការបញ្ចប់នូវអំណាចរបស់សហកម្មសិទ្ធិករណាមួយ ។ ក្នុងករណីដែលគណនីសហកម្មសិទ្ធិ គឺជាគណនីចរន្តរួមជាមួយនឹងមធ្យោបាយផ្សេងៗរបស់ធនាគារ យើងខ្ញុំយល់ព្រមថា ក្រោយពីមរណៈភាពរបស់នរណាម្នាក់ក្នុងចំណោមពួកយើង ធនាគារមានសិទ្ធិបង្កកគណនីខាងលើ និងសំរេចនូវសកម្មភាពដែលត្រូវអនុវត្តបន្តទៀតតាមឆន្ទានុសិទ្ធិដាច់ខាត និងតែមួយគត់របស់ខ្លួន ។

(គ) យោងតាមប្រការ គ.២.១ និង ២.២ខាងលើ ក្នុងករណីក្ស័យធន ធនាគារអាចធ្វើតាមឆន្ទានុសិទ្ធិ ដាច់ខាតរបស់ខ្លួន ដោយយោងតាមការស្នើសុំរបស់នរណាម្នាក់ក្នុងចំណោមពួកយើង អោយតែយើងខ្ញុំ រឺនរណាម្នាក់ក្នុងចំណោមពួកយើងដែលជាភាគីគ្មានកំហុស នោះធនាគារអាចអនុញ្ញាតអោយដកប្រាក់ (ក្នុងករណីដែល ធនាគារអនុញ្ញាតអោយយើងខ្ញុំ រឺនរណាម្នាក់ក្នុងចំណោមពួកយើងអោយមាន សិទ្ធិដកប្រាក់តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ខ្លួន) នូវចំនួនទឹកប្រាក់ពីគណនីសហកម្មសិទ្ធិតាមតែធនាគារយល់ថាសមស្រប តាមតែឆន្ទានុសិទ្ធិដាច់ខាត របស់ខ្លួន ។

## ១០. បញ្ញើមូលប្បទានប័ត្រដោយម៉ាស៊ីនបញ្ញើ រឺប្រអប់បញ្ញើ

១០.១ ខ្ញុំ/យើងខ្ញុំអនុញ្ញាតអោយធនាគារទទួលនូវបញ្ញើមូលប្បទានបត្រ័ចូលទៅក្នុងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ ដែលត្រូវបានធ្វើបញ្ញើតាមម៉ាស៊ីនបញ្ញើ រឺប្រអប់បញ្ញើដែលផ្តល់ដោយធនាគារភ្ជាប់ជាមួយនឹងស្រោមសំបុត្រ និង/រឺបែបបទលិខិតបញ្ញើដែលកំណត់ដោយធនាគារ (ប្រសិនបើមាន) ។ ខ្ញុំ/យើងខ្ញុំយល់ព្រមដែរថា បង្កាន់ដៃណាមួយដែលបានបោះពុម្ពដោយម៉ាស៊ីនបញ្ញើមូលប្បទានប័ត្រ គឺជាភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា មូលប្បទានប័ត្រត្រូវបានធ្វើបញ្ញើនៅក្នុងម៉ាស៊ីនខាងលើ ហើយធនាគារមិនទទួលខុសត្រូវចំពោះខ្ញុំ/យើងខ្ញុំ ប្រសិនបើមូលប្បទានប័ត្រមិនបានដាក់នៅក្នុងស្រោមសំបុត្រដែលបានកំណត់ រឺតាមបែបបទលិខិតបញ្ញើ ដែលមិនបានបំពេញនូវព័ត៌មានពេញលេញ រឺបែបបទលិខិតចែងខាងលើត្រូវបានបំពេញខុស រឺលេខគណនីមិនត្រឹមត្រូវ និង/រឺឈ្មោះត្រូវបានបំពេញនៅពេលធ្វើបញ្ញើមូលប្បទានបត្រ័ រឺប្រសិនបើលេខគណនី ឈ្មោះ រឺចំនួនទឹកប្រាក់ ត្រូវបានបំពេញខុសនៅលើម៉ាស៊ីនបញ្ញើ មូលប្បទានប័ត្រ ។

១០.២ ខ្ញុំ/យើងខ្ញុំយល់ព្រមដែរថា មូលប្បទានប័ត្រត្រូវបានបញ្ញើតាមយៈម៉ាស៊ីនបញ្ញើមូលប្បទានប័ត្រ រឺប្រអប់បញ្ញើមូលប្បទានប័ត្ររហ័ស (Fast Cheque Deposit Boxes) ដោយគ្មានភ្ជាប់ជាមួយស្រោម សំបុត្រ រឺ/និងលិខិតបញ្ញើមូលប្បទានប័ត្រ និង/រឺឈ្មោះ និង/រឺលេខគណនីរបស់អត្ថគាហក មិនត្រូវបានសរសេរ រឺបំពេញ លើលិខិតបញ្ញើមូលប្បទានប័ត្រ រឺ/និង នៅខាងក្រោយខ្នងរបស់មូលប្បទានប័ត្រ និង/រឺស្រោមសំបុត្រ មិនត្រូវបានបោះត្រា និង/រឺមូលប្បទានប័ត្រមិនបានដាក់បញ្ញើនៅក្នុងប្រអប់ត្រឹមត្រូវ និង/រឺវាមានភាពខុសគ្នារវាងឈ្មោះ និងលេខគណនីនៅលើលិខិតបញ្ញើមូលប្បទានប័ត្រ ហើយមូលប្បទានប័ត្រដែលត្រូវបានបញ្ញើ រឺលេខគណនី ឈ្មោះ និងចំនួនទឹកប្រាក់ ត្រូវបានបំពេញខុសនៅលើម៉ាស៊ីនបញ្ញើមូលប្បទានប័ត្រ រឺមូលប្បទានប័ត្រ គឺជាមូលប្បទានប័ត្រ "សាច់ប្រាក់" (ពីនេះតទៅហៅរួមគ្នាថា "ភាពមិនប្រក្រតី") ដូច្នេះធនាគារមាន សិទ្ធិអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការធ្វើបេឡានិច័យ រឺមិនធ្វើបេឡានិច័យចំពោះមូលប្បទានប័ត្រនេះ ។

១០.៣ នៅក្នុងករណីដែល ធនាគារអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការធ្វើបេឡានិច័យលើមូលប្បទានប័ត្រទាំងនេះ ដោយភ្ជាប់ជាមួយនឹងភាពមិនប្រក្រតី ប្រតិលាភរបស់មូលប្បទានប័ត្រ ដែលត្រូវបានធ្វើបេឡានិច័យដោយធនាគារ នឹងបានធ្វើជាឥណទានចូលទៅក្នុងគណនីចំរុះរបស់ឥណទាយក (Sundry Creditors Account) រក្សាទុកដោយសាខារបស់ធនាគារនីមួយៗ ។ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា ប្រតិលាភដែលទទួលបានពីមូលប្បទានប័ត្រខាងដើមត្រូវតែរក្សាទុកនៅក្នុងគណនីចំរុះរបស់ឥណទាយករហូតដល់ពេលដែលខ្ញុំ/យើងខ្ញុំស្នើសុំទាមទារនូវចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងមូលប្បទានប័ត្រខាងដើម ក្រោយពីពេលដែលខ្ញុំ/យើងខ្ញុំបានបង្ហាញភស្តុតាង និង/រឺ ឯកសារផ្សេងៗតាមការពេញចិត្តរបស់ធនាគារ ។

១០.៤ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា ធនាគាររក្សាសិទ្ធិក្នុងការស្នើសុំនូវឯកសារ និង/រឺភស្តុតាងបន្ថែមផ្សេង ទៀត ប្រសិនបើធនាគារយល់ថាសមស្រប ។

## ១១. ការផ្ទេរមូលនិធិពីគណនីធនាគារតាមរយៈម៉ាស៊ីន ATM

នៅក្នុងករណីដែល ខ្ញុំ/យើងខ្ញុំ ផ្ទេរមូលនិធិពីគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំណាមួយទៅគណនីណាមួយរបស់ខ្ញុំ/យើងខ្ញុំ រឺទៅគណនីណាមួយរបស់ភាគីទីបី ខ្ញុំ/យើងខ្ញុំយល់ព្រមថា ចំនួនទឹកប្រាក់ត្រូវបានធ្វើឥណពន្ធ ដោយស្វ័យប្រវត្តពីគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ បន្ទាប់ពីបញ្ចប់សព្វគ្រប់នូវប្រតិបត្តិការ និងត្រូវបានចាត់ទុកថាបានផ្ទេរទៅក្នុងគណនីទទួលរួចរាល់ ហើយខ្ញុំ/យើងខ្ញុំមិនមានសិទ្ធិស្នើសុំអោយធនាគារផ្តល់សំណងមកវិញ រឺធ្វើឥណទានមកវិញចូលក្នុងគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ ទោះតាមមូលហេតុណាក៏ដោយ ។

## ១២. របាយការណ៍គណនី

១២.១ ធនាគារ នឹងផ្តល់អោយខ្ញុំ/យើងខ្ញុំ នូវរបាយការណ៍សមតុល្យគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ នៅពេល ណាដែលធនាគារ យល់ថា សមស្របក្នុងការផ្តល់ជូនជាប្រចាំ ។

១២.២ ខ្ញុំ/យើងខ្ញុំយល់ព្រមពិនិត្យ និងជូនដំណឹងទៅធនាគារពីកំហុស ភាពមិនប្រក្រតី ភាពខុសគ្នា ការទាមទារ រឺឥណពន្ធ រឺករណីណាមួយដែលមិនទទួលបានការអនុញ្ញាត ទោះបីជាត្រូវបានធ្វើឡើង អនុវត្ត រឺបង់ប្រាក់ ដែលកើតពីការបន្លំការក្លែង គ្មានសមត្ថកិច្ច ការធ្វេសប្រហែស រឺករណីផ្សេងទៀត ។

១២.៣ ខ្ញុំ/យើងខ្ញុំយល់ព្រមផងដែរថា ប្រសិនបើខ្ញុំ/យើងខ្ញុំមិនបានផ្តល់ដំណឹងជូនធនាគារជាលាយលក្ខណ៍អក្សរ ពីការមិនបានទទួល និង បានទទួលនូវរបាយការណ៍ពីធនាគារ រឺជូនដំណឹងពីកំហុស ភាពមិនប្រក្រតី ភាពខុសគ្នា ការទាមទារ រឺឥណពន្ធ រឺករណីណាមួយដែលមិនទទួលបានការអនុញ្ញាត រឺករណីផ្សេងៗនៅក្នុងរបាយការណ៍ ក្នុងរយៈពេល ២១ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចេញរបាយការណ៍ គណនីធនាគារ រឺកំណត់ត្រាទាំងអស់ ត្រូវបានចាត់ទុកថាជាភស្តុតាងពេញលេញសម្រាប់ការបញ្ចូលគ្រប់ប្រតិបត្តិការ និងសមតុល្យ នៅក្នុងគណនីទាំងនេះ ហើយខ្ញុំ/យើងខ្ញុំត្រូវបានចាត់ទុកថាបានទទួលស្គាល់នូវរាល់បញ្ហាដែលមានចែងនៅក្នុងរបាយការណ៍ថា ជាការពិត និងត្រឹមត្រូវគ្រប់យ៉ាង ។ រាល់ការកែ ប្រែក្រោយពីនេះ គឺស្ថិតនៅក្រោមឆន្ទានុសិទ្ធិ តែមួយគត់របស់ធនាគារ ។

## ១៣. វិធាន និងបញ្ញត្តិនៃស្ថាប័ននិយ័តកម្ម

ខ្ញុំ/យើងខ្ញុំយល់ព្រមថា បន្ថែមលើសពីនេះ និង ដោយមិនគិតពីលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌជាធរមាន នោះលក្ខខណ្ឌទាំងនេះត្រូវបានគ្រប់គ្រង និង ត្រូវស្របទៅវិធាន បទបញ្ញត្តិ និងការណែនាំជានិច្ចជាកាលចេញដោយធនាគារជាតិនៃកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា ទោះបីជាវិធានបញ្ញត្តិ និងការណែនាំទាំងនេះ មានរឺគ្មាន អំណាចផ្លូវច្បាប់ក៏ដោយ ។ ខ្ញុំ/យើងខ្ញុំយល់ព្រមថា សេវាកម្មនានាដែលកំពុងមាន និងបន្តមាន នាពេលបច្ចុប្បន្ន និង/រឺបន្ទាប់ពីនេះម្តងម្កាល រឺនៅពេលណាក៏ដោយដែលធនាគារផ្តល់អោយខ្ញុំ/យើងខ្ញុំ ត្រូវតែស្របទៅតាម វិធាន បញ្ញត្តិ និងការណែនាំខាងលើ ។

## ១៤. អនុទ្ទេសអចិន្ត្រៃយ៍ ប្រតិបត្តិការធនាគារ និងការប្រាក់

១៤.១ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់ការបង់ប្រាក់ ការផ្ទេរមូលនិធិ រឺការបំពេញអនុភាពដោយយោងទៅតាម អនុទ្ទេសអចិន្ត្រៃយ៍ដែលផ្តល់អោយធនាគារអាចធ្វើបាន ដរាបណាគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំមានសមតុល្យអប្បបរមាដែលកំណត់ជាប្រចាំដោយធនាគារ ។

១៤.២ ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់ប្រតិបត្តិការដែលធ្វើឡើងជាមួយធនាគារ ត្រូវតែបង្ហាញជាភស្តុតាងនូវអត្តសញ្ញាណ ហើយធនាគារមានឆន្ទានុសិទ្ធិស្នើសុំ និងធ្វើការបញ្ជាក់ទៅតាមគ្រប់មធ្យោបាយដែលធនាគារយល់ ថាសមស្រប រួមមានតែមិនកម្រិតត្រឹម ការផ្តល់អត្តសញ្ញាណ តាមរយៈការផ្ទៀងផ្ទាត់ស្នាមមេដៃផ្ទាល់ និង តាមប្រព័ន្ធអេឡិចត្រូនិច រឺឌីជីថល រឺតាមមធ្យោបាយ វិធី រឺបែបបទផ្សេងទៀតដែលធនាគារយល់ថាសមស្រប និងដែលអនុវត្តជាប្រចាំ ។ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមិនទទួលខុសត្រូវចំពោះខ្ញុំ/យើងខ្ញុំ ដោយពឹងផ្អែកទៅលើ វិធីបញ្ជាក់ រឺដំណើរការ ក្នុងការអនុវត្តប្រតិបត្តិការធនាគារទាំងនេះឡើយ ។

១៤.៣ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ការប្រាក់លើគណនីធនាគារត្រូវបានបង់ជូនតាមកម្រិតអត្រាការប្រាក់ និងលក្ខខណ្ឌ ដូចដែលបានផ្សព្វផ្សាយ រឺជូនដំណឹងដោយធនាគារ ម្តងម្កាលប៉ុណ្ណោះ។ ការប្រាក់នេះ អាចត្រូវបានកំណត់ចំពោះគណនីជាក់លាក់ណាមួយ រឺត្រូវមានសមតុល្យអប្បបរមាដែលត្រូវរក្សាទុកនៅធនាគារ ។

## ១៥. លក្ខខណ្ឌពិសេស

ខ្ញុំ/យើងខ្ញុំយល់ព្រមថា ក្រៅពីអ្វីដែលមានចែងនៅក្នុងលក្ខខណ្ឌសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃ គណនី ធនាគារជាក់លាក់ណាមួយ រឺការប្រើប្រាស់នូវកាតណាមួយដែលចងភ្ជាប់ទៅនឹងគណនីធនាគារណាមួយរបស់ ខ្ញុំ/ យើងខ្ញុំ ដូចដែលបានចែងនៅក្នុងឯកសារផ្សេងទៀត ដែលបានប្រើពាក់ព័ន្ធនឹងគណនីធនាគារ រឺកាត រឺដូចដែលបានចែងនៅក្នុងលិខិតជូនដំណឹង រឺក្នុងសៀវភៅគណនីសន្សំ រឺបង្កាន់ដៃប្រាក់បញ្ញើមានពេលកំណត់ ខិត្តប័ណ្ណ រឺការផ្សព្វផ្សាយរបស់ធនាគារដែលកំណត់ពីលក្ខខណ្ឌបន្ថែមជាធរមាន ត្រូវយកមកអនុវត្ត ហើយក្នុងករណីដែលមានភាពខុសគ្នា នោះអ្វីដែលមានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង រឺក្នុងសៀវភៅគណនីសន្សំ រឺបង្កាន់ដៃ ប្រាក់បញ្ញើ មានពេលកំណត់ ខិត្តប័ណ្ណ រឺការផ្សព្វផ្សាយរបស់ធនាគារដែលកំណត់ពីលក្ខខណ្ឌបន្ថែមជាធរមានទាំងនេះ ត្រូវបាន យកជាគោល ។

## ១៦. ការបកស្រាយ

ពាក្យ "គណនីធនាគារ" សំដៅរាល់ប្រភេទនៃគណនីសន្សំ គណនីចរន្ត គណនីប្រាក់បញ្ញើមានរយៈពេលកំណត់ និងគណនីផ្សេងៗទៀតដែលផ្តល់ដោយធនាគារ ហើយខ្ញុំ/យើងខ្ញុំរក្សាទុកជាមួយធនាគារ រួមមានតែ មិនកម្រិតត្រឹម គណនីសន្សំ ជាមួយលក្ខណៈពិសេសនៃគណនីចរន្ត និងប្រសិនបើយោងទៅតាមបរិបទណាមួយដែលសំដៅទៅលើគណនីណាមួយក្នុងចំណោមគណនីទាំងអស់ ។

## ១៧. គណនីអនាគត

ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់ការលុបចោល រឺការកែប្រែលក្ខខណ្ឌខាងលើ រួមជាមួយនឹងលក្ខខណ្ឌបន្ថែម ផ្សេងទៀត ត្រូវតែអនុវត្តចំពោះគណនីអនាគតទាំងអស់ដែលខ្ញុំ/យើងខ្ញុំរក្សាទុកជាមួយធនាគារ ។

## ១៨. ការកែប្រែលក្ខខណ្ឌ

ខ្ញុំ/យើងខ្ញុំទទួលស្គាល់ថា មានលក្ខខណ្ឌផ្សេងទៀតជាច្រើន ហើយធនាគាររក្សាសិទ្ធិក្នុងការបន្ថែម លុប ចោល រឺកែប្រែលក្ខខណ្ឌណាមួយខាងលើ ហើយខ្ញុំ/យើងខ្ញុំយល់ព្រមអនុវត្តតាមលក្ខខណ្ឌ៍ដែលបានបន្ថែម លុបចោល រឺកែប្រែទាំងនោះ ហើយខ្ញុំ/យើងខ្ញុំបានទទួលដឹងឮតាមរយៈការដាក់តាំងបង្ហាញនៅធនាគារ រឺនៅសាខាធនាគារ រឺផ្ញើតាមប្រៃសនីយ៍ទៅអាសយដ្ឋានចុះបញ្ជីចុងក្រោយគេបង្អស់របស់ខ្ញុំ/យើងខ្ញុំជាមួយធនាគារ រឺផ្សព្វផ្សាយតាមរយៈវិធីផ្សេងទៀតដែលធនាគារយល់ថាសមស្រប ។

## ១៩. សុពលភាពនៃការយល់ព្រមលើលក្ខខណ្ឌ

ខ្ញុំ/យើងខ្ញុំយល់ព្រមថា រាល់ការចុះហត្ថលេខានៅលើពាក្យស្នើសុំបើកគណនីធនាគារ គឺជាការផ្តល់នូវការយល់ព្រមលើលក្ខខណ្ឌទាំងឡាយរបស់ធនាគារ និងរាល់ការកែប្រែដែលអាចនឹងកើតមាននៅ ពេលខាងមុខ ។

## ២០. សិទ្ធិរបស់ធនាគារក្នុងការបដិសេធនូវប្រតិបត្តិការណាមួយ

ខ្ញុំ/យើងខ្ញុំយល់ព្រមថា ក្នុងករណីដែលផ្ទុយនឹងលក្ខខណ្ឌខាងលើ ធនាគារមានសិទ្ធិមិនទទួលដាច់ខាតនូវប្រាក់បញ្ញើនានា រឺមូលប្បទានប័ត្រ និង/រឺមិនអនុញ្ញាត រឺអនុវត្តនូវប្រតិបត្តិការផ្សេងទៀតរួមមានតែមិនកម្រិតត្រឹម ការដកប្រាក់ពីគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ ការផ្ទេរប្រាក់គ្រប់ប្រភេទ សេវាកម្មផ្ទេរប្រាក់ (Telegraphic Transfer) ពី រឺទៅគណនីធនាគាររបស់ខ្ញុំ/យើងខ្ញុំ និងដោយមិនបាច់ផ្តល់មូលហេតុណាមួយឡើយ ។

## ២១. ការបង្ហាញព័ត៏មាន

ខ្ញុំ/យើងខ្ញុំយល់ព្រម និងអនុញ្ញាតអោយធនាគារបង្ហាញព័តិមានទៅបុគ្គលណាមួយ រួមមានតែមិនកម្រិតត្រឹម ធនាគារជាតិនៃកម្ពុជា នូវព័តិមានដែលទាក់ទងទៅនឹងកិច្ចការរបស់ខ្ញុំ/យើងខ្ញុំ និង/រឺព័តិមានគណនីធនាគារ និង/រឺមធ្យោបាយឥណទានដែលត្រូវបានទាមទារ ទោះបីដោយច្បាប់ រឺករណីផ្សេងទៀតក្នុងបំណងណាមួយដែលធនាគារយល់ថាសមស្របនិងចាំបាច់។ ខ្ញុំ/យើងខ្ញុំយល់ព្រមថា ធនាគារមិនទទួលខុសត្រូវឡើយ ចំពោះការបង្ហាញព័តិមាននេះ ទោះដោយផ្ទាល់ រឺដោយប្រយោលក្តី ។

## ២២. ភាសា

ក្នុងករណីដែលមានភាពមិនស្របគ្នា មានមន្ទិលសង្ស័យ រឺ មានភាពមិនច្បាស់លាស់រវាងភាសាខ្មែរ និង ភាសាអង់គ្លេសចំពោះលក្ខខណ្ឌទាំងនេះ ខ្ញុំ/យើងខ្ញុំយល់ព្រមទទួលយកភាសាអង់គ្លេសមកអនុវត្តជាគោល ។